ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ ៖ **៥៩៧ "ក្រ៨៣"**
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៥
ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ ២៤៦
ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ១៨១០
ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩ព្រឹក នៅ សាលសវនាការទី៤ ដោយមានសមាសភាព ៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៥ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ ដែលមាន ៖

១- ជនជាប់ចោទឈ្មោះ [redacted] **ចន្នី** ភេទ ប្រុស អាយុ ២៧ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ស្ពឺ អាសយដ្ឋានមុនពេលឃុំខ្លួនស្នាក់នៅបន្ទប់ជួល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] និម "រ" ម្តាយឈ្មោះ [redacted] ផល "រ" នៅលីវ ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ ៖ ធ្លាប់ជាប់ពន្ធនាគារពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

ឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៥៩ "ជ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២៣ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) ។

២- ជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទ ប្រុស អាយុ ២៧ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ កម្មករ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ អាសយដ្ឋានមុនពេលឃុំខ្លួនស្នាក់នៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សារឿន "ស" ម្តាយឈ្មោះ [redacted] អាន "ស" ប្រពន្ធឈ្មោះ [redacted] ស្រីនុត មានកូនចំនួន ០១នាក់ ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ ៖ ពុំមាន ។

ឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៦២ "ជ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២៣ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) ។

៣- ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនឈឿន** ភេទ ប្រុស អាយុ ២៩ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ ជាងដែក ទីកន្លែងកំណើត នៅ[redacted] ខេត្តកណ្តាល អាសយដ្ឋានមុនពេលឃុំខ្លួនស្នាក់នៅភូមិសំរោងជើង

Scanned with CamScanner

សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]វិឆៃ "រ" ម្តាយឈ្មោះ [redacted]ស៊ីនួន "រ" ប្រពន្ធឈ្មោះ [redacted]រី គ្មានកូន ជានីតិជន។
ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ ៖ ធ្លាប់ជាប់ពន្ធនាគារពីបទ លួច។
ឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៦០ "ជ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២៣ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) ។

៤-ជនជាប់ចោទឈ្មោះ [redacted]តាំ ភេទ ប្រុស អាយុ ៣៧ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ លក់ការ្ហូ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល អាសយដ្ឋានមុនពេលឃុំខ្លួនស្នាក់នៅភូមិគ្រួស សង្កាត់សំរោងទង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] សាមី "ស" ម្តាយឈ្មោះ [redacted] តាយ "រ" នៅលីវ ជា នីតិជន។
ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ ៖ ពុំមាន ។
ឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៦១ "ជ១" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២៣ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) ។

ត្រូវបានជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចវត្តក្រគៀត ផ្លូវជាតិលេខ៣ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។
មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]តាំ និងឈ្មោះ[redacted] ប៊ុនឈឿន
មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តាំ ឈ្មោះ [redacted] ប៊ុនឈឿន ឈ្មោះ[redacted] ចន្ធី និងឈ្មោះ[redacted] វាសនា

អត្ថហេតុនៃរឿងអាងដូចតទៅ

កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ១២ និង៣០នាទី នៅចំណុចវត្តក្រគៀត ផ្លូវជាតិលេខ៣ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែន ជ័យ រាជធានីភ្នំពេញ មានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចន្ធី ឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted]តាំ បានទំនាក់ទំនងកម្មង់គ្រឿងញៀនពីឈ្មោះ [redacted] ប៊ុនឈឿន ដើម្បីយកមកចែកចាយបន្ត។ លុះដល់វេលាម៉ោង ១៥ និង៣០នាទី ឈ្មោះ[redacted] ប៊ុនឈឿន ក៏បានទៅយកគ្រឿងញៀនពីឈ្មោះ ថុង រួចក៏បានបបួលឈ្មោះ[redacted]តាំ យកគ្រឿងញៀនដែលគេបានកុម្មង់ ពេលទៅដល់ទីតាំងដែលបានណាត់ជួបដើម្បីយកគ្រឿងញៀននោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ធ្វើការឃាត់ខ្លួនជនសង្ស័យទាំងបួននាក់ខាងលើតែម្តង។
បានឃើញ របាយការណ៍លេខ ៥៥ រ.ប.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ របស់មន្ទីរប្រឆាំងគ្រឿងញៀន។
បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៨៩ អ.យ.ដ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។
បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ១៤៣០ អ.យ.ដ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣។
បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៨៨៦ "ច" ដ.ដ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **តាំ** បានឆ្លើយថា ៖ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ នៅថ្ងៃឃាត់ខ្លួននោះ ឈ្មោះ [redacted]ប៊ុនឈឿន បានបបួលខ្លួនថា ទៅហូបអីជាមួយគ្នានៅស្ងួចព្រាក់ ខ្លួនក៏ទៅជាមួយដោយពុំបានដឹងអ្វីឡើយ ពេលទៅដល់ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួន និងឈ្មោះ [redacted] ប៊ុនឈឿន តែម្តង។ ខ្លួនពុំដែលស្គាល់ឈ្មោះ [redacted] វាសនា និងឈ្មោះ[redacted]ចន្ធី ឡើយ។ ពីមុនមកខ្លួនពិតជាធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ [redacted] ប៊ុនឈឿន ក្នុងតម្លៃ ១០០០០រៀល ទៅ ២០០០០រៀល យកទៅប្រើប្រាស់មែន។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនពុំមានគ្រឿងញៀននៅជាប់នឹងខ្លួនទេ។ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាទិញគ្រឿងញៀនយកមកប្រើ

Scanned with CamScanner

ប្រាស់មែន តែពុំធ្លាប់ជួញដូរគ្រឿងញៀនឡើយ។ ខ្លួន និងឈ្មោះ [redacted] ប៊ុនឈឿន ពិតជាធ្លាប់ចូលលុយគ្នាមួយម៉ឺន ពីរម៉ឺនរៀល ទិញគ្រឿងញៀនយកមកជក់ជាមួយគ្នាមែន។

-ជនជាប់ចោទឈ្មោះ [redacted] **វាសនា** បានឆ្លើយថា ៖ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយខ្លួនធ្លាប់ទិញគ្រឿងញៀនយកទៅលក់បន្តបានចំនួន ២ ទៅ ៣ដងហើយ ដោយក្នុងម្តងៗ ខ្លួនទិញចំនួន ៤០០០០០ រៀល ឬក៏ ៥០០០០០រៀល ឬក៏ ៦០០០០០រៀល។ ថ្នាំញៀនដែលដកហូតបានមកនេះមានរបស់ខ្លួនតែបន្តិចទេ ក្រៅពីនោះជារបស់ឈ្មោះ [redacted] ចន្ធី។ ខ្លួនទិញលក់គ្រឿងញៀនបានប្រហែលជាបួនខែទើបត្រូវឃាត់ខ្លួននេះ។ ក្នុងរឿងនេះ សមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] ចន្ធី មុនគេ ទើបមកឃាត់ខ្លួនខ្ញុំ ហើយបន្តទៅឃាត់ខ្លួនឈ្មោះ [redacted] ប៊ុនធឿន និងឈ្មោះ [redacted] តាំ។ នៅពេលឃាត់ខ្លួន នៅនឹងខ្លួនមានគ្រឿងញៀនមួយកញ្ចប់ដែលខ្លួនទិញមកទុកជក់។ សមត្ថកិច្ចដកហូតគ្រឿងញៀនពីខ្លួនប្រហែលជាទម្ងន់មួយជ្រុង ឬកន្លះជ្រុងប៉ុណ្ណោះ។ ខ្លួនមានការសោកស្តាយកំហុសនេះហើយ ខ្លួនរាងចាលហើយលែងហ៊ានប្រព្រឹត្តទៀតហើយ។

-ជនជាប់ចោទឈ្មោះ [redacted] **ចន្ធី** បានឆ្លើយថា ៖ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយខ្លួនបានកុម្មង់ទិញគ្រឿងញៀនពីឈ្មោះ [redacted] វាសនា ចំនួន ៦០០០០០រៀល។ ខ្លួនពីឈ្មោះ [redacted] វាសនា យកគ្រឿងញៀនឱ្យម្តង ៦០០០០០រៀល ដោយមិនដឹងឈ្មោះ [redacted] វាសនា ទៅយកពីនរណាមកទេ។ ខ្លួនទិញពីឈ្មោះ [redacted] វាសនា មកដើម្បីលក់បន្ត តែពុំស្គាល់ឈ្មោះអ្នកមកទិញទេ។ រឿងនេះដំបូងមានគេតេមកទិញគ្រឿងញៀនពីខ្លួនក្នុងតម្លៃ ៥០០០០រៀល ទើបសមត្ថកិច្ចឈានដល់ការឃាត់ខ្លួនតែម្តង។ បន្ទាប់ពីឃាត់ខ្លួនហើយ ទើបសមត្ថកិច្ចទៅឃាត់ខ្លួនឈ្មោះ [redacted] វាសនា។ ពីមុនមកធ្លាប់មានការទិញគ្រឿងញៀនពីឈ្មោះ [redacted] វាសនា មែន តែពុំដែលទិញពីឈ្មោះ [redacted] តាំ ឡើយ។ ខ្លួនសារភាពថាពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ក្រោយពីបានប្រព្រឹត្តអំពើនេះហើយពេលនេះខ្លួនបានដឹងពីកំហុសរបស់ខ្លួន និងសុំកែប្រែខ្លួនឡើងវិញ។ ខ្លួនគ្រាន់តែបានប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះ ខ្លួនចង់កែប្រែខ្លួនឡើងវិញ។

-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនឈឿន** បានឆ្លើយថា ៖ ខ្លួនពិតបានប្រព្រឹត្តដូចការចោទប្រកាន់មែន នៅថ្ងៃដែលត្រូវឃាត់ខ្លួន ខ្លួនបានបបួលឈ្មោះ [redacted] តាំ ទៅហួបអីនៅស្ទូចព្រាក់ ពេលទៅដល់ស្រាប់តែមានសមត្ថកិច្ចឃាត់ខ្លួនទាំងខ្លួន និងឈ្មោះ [redacted] តាំ តែម្តង។ ខ្លួនប្រើប្រាស់គ្រឿងញៀនដោយចូលលុយជាមួយឈ្មោះ [redacted] តាំ មួយម៉ឺនរៀល ទៅ ពីរម៉ឺនរៀល ទិញមកប្រើប្រាស់រួមគ្នា ដោយធ្លាប់ទិញពីឈ្មោះ [redacted] ចន្ធី បានពីរដងដែរ។ ខ្លួនស្គាល់ឈ្មោះ [redacted] ចន្ធី ប្រហែល ១ខែ ទៅ ២ខែហើយ។ នៅដំណាក់កាលសមត្ថកិច្ចគេបានវាយខ្លួនផងឆក់ខ្លួនផងក្នុងការសួរចម្លើយឱ្យខ្លួនសារភាពទទួលយកកំហុស។ ខ្លួនពិតជាប្រាប់ឈ្មោះ [redacted] តាំ ថា ទៅស្ទូចព្រាក់ញ៉ាំអីមែន។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤០៥៣០/២៣ ម.ព.អ.ជ.ប.ត.ញ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤០៥៣១/២៣ ម.ព.អ.ជ.ប.ត.ញ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ១៤៥ រ.វ.ត/២៣ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

សេចក្តីសន្និដ្ឋានឆ្លើងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការនេះរួចមកឃើញថា តាមចម្លើយរបស់ជនជាប់ចោទទាំងបួននាក់នេះ មានភាពស៊ីសង្វាក់ទៅនឹងការបង្ក្រាបជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងស៊ីសង្វាក់ទៅនឹងភស្តុតាងជាគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទ ដែលអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ចន្ធី ឈ្មោះ [redacted] ប៊ុនឈឿន ឈ្មោះ [redacted]

វាសនា និងឈ្មោះ [redacted] តាំ ពិតជាបានប្រព្រឹត្តនូវអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់មែន ហេតុនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់លើជនជាប់ចោទទាំងបួនាក់ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ១៤៣០ អ.យ.ផ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ទុកនៅដដែលទាំងស្រុង និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តាំ និងឈ្មោះ [redacted] ប៊ុនឈឿន បានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការនេះ រួចមកឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] តាំ ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ជាក់ស្តែងនៅថ្ងៃដែលត្រូវឃាត់ខ្លួន ឈ្មោះ [redacted] តាំ គ្រាន់តែត្រូវបានឈ្មោះ [redacted] ប៊ុនឈឿន បបួលទៅហូបអីនៅស្ងួចប្រាក់ប៉ុណ្ណោះ ឈ្មោះ [redacted] ប៊ុនឈឿន ក៏បានឆ្លើយបញ្ជាក់ហើយដែរថា ឈ្មោះ [redacted] តាំ ពុំបានដឹងអ្វីទេ គឺខ្លួនជាអ្នកបបួលឈ្មោះ [redacted] តាំ ទៅហូបអីនៅស្ងួចប្រាក់។ ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] ប៊ុនឈឿន ក៏ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ដែរ ជាក់ស្តែងនៅថ្ងៃកើតហេតុគឺឈ្មោះ [redacted] ប៊ុនឈឿន ទៅហូបអីនៅស្ងួចប្រាក់ប៉ុណ្ណោះក៏ត្រូវឃាត់ខ្លួនដោយពុំមានដកហូតបានគ្រឿងញៀនពីខ្លួនឡើយ ។ សំណូមពរ សុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] តាំ និងឈ្មោះ [redacted] ប៊ុនឈឿន រួចផុតពីបទចោទប្រកាន់បទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តាំ និងឈ្មោះ [redacted] ប៊ុនឈឿន ឈ្មោះ [redacted] ចន្ធី និងឈ្មោះ [redacted] វាសនា បាន ធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការនេះ រួចមកឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ចន្ធី បានសារភាពរួចហើយថា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ប៉ុន្តែ អំពើរបស់កូនក្តីខ្លួននេះគឺស្ថិតក្នុងភាពតិចតួចណាស់ ពុំបានធ្វើឡើងធំដុំឡើយ ហើយក៏ពុំមានជនរងគ្រោះផងដែរ ម្យ៉ាងទៀត គាត់បានដឹងពីកំហុស និងបានស្នើសុំតុលាការកែប្រែខ្លួនឡើងវិញទៀតផង។ ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] វាសនា ក៏បានសារភាពនូវអំពើរបស់គាត់ផងដែរ អំពើនោះក៏មានទំហំតូចតាច ពុំមានអ្វីធំដុំទេ។ សំណូមពរ សុំឱ្យតុលាការសម្រាលទោសដល់កូនក្តីខ្លួនឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] ចន្ធី។ ចំណែកកូនក្តីខ្លួនឈ្មោះ [redacted] តាំ និងឈ្មោះ [redacted] ប៊ុនឈឿន គឺពុំមានជាប់ពាក់ព័ន្ធនឹងបទល្មើសឡើយ គាត់ទាំងពីរគ្រាន់តែទៅហូបអីហៅហាងស្ងួចប្រាក់ ក៏ត្រូវឃាត់ខ្លួន។ សំណូមពរ សុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] តាំ និងឈ្មោះ [redacted] ប៊ុនឈឿន រួចផុតពីបទចោទប្រកាន់បទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

សំដីចុងក្រោយបង្ហស់របស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **វាសនា** បាននិយាយសំដីចុងក្រោយបង្ហស់ថា ៖ សុំសម្រាលទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] **ចន្ធី** បាននិយាយសំដីចុងក្រោយបង្ហស់ថា ៖ សុំសម្រាលទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] **តា** បាននិយាយសំដីចុងក្រោយបង្ហស់ថា ៖ សុំរកយុត្តិធម៌ដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនឈឿន** បាននិយាយសំដីចុងក្រោយបង្ហស់ថា ៖ សុំជួយលើកលែងការចោទប្រកាន់ដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

សំអាងហេតុ

១. **ឃើញថា** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៨៨៦ "ច" ដ.ដ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ចន្ធី ភេទ ប្រុស អាយុ ២៧ឆ្នាំ ឈ្មោះ [redacted] វាសនា ភេទ ប្រុស អាយុ ២៧ឆ្នាំ ឈ្មោះ [redacted] ប៊ុនឈឿន ភេទ ប្រុស អាយុ ២៩ឆ្នាំ និងឈ្មោះ [redacted] តាំ ភេទ ប្រុស អាយុ ៣៣ឆ្នាំ មកជំនុំជម្រះតាមបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចវត្តក្រគៀត ផ្លូវជាតិ លេខ៣ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ បទ ល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. **ឃើញថា** គ្រឿងញៀនដែលមន្ត្រីនគរបាលយុត្តិធម៌ឆែកឆេររកឃើញពីជនជាប់ចោទឈ្មោះ [redacted] ចន្ធី និងឈ្មោះ [redacted] ប៊ុនឈឿន ជាក្រមពណ៌សថ្លាទម្ងន់ ១៧,១៧ (ដប់ប្រាំពីរក្បៀសដប់ប្រាំពីរ) ក្រាម នេះគឺជាសារធាតុញៀន មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធចំនួន ៧៥,៣៦ (ចិតសិបប្រាំក្បៀសសាមសិបប្រាំមួយ) ភាគរយ ស្ថិត ក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤០៥៣០/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣។ ហេតុនេះសារធាតុញៀនប្រភេទ មេតំហ្វេតាមីន មានកម្រិតភាពសុទ្ធគិតជា ទម្ងន់ [(១៧,១៧ x ៧៥,៣៦)/១០០] = ១២,៩៣ (ដប់ពីរក្បៀសកៅសិបបី)ក្រាម។

៣. **ឃើញថា** គ្រឿងញៀនដែលមន្ត្រីនគរបាលយុត្តិធម៌ឆែកឆេររកឃើញពីជនជាប់ចោទឈ្មោះ [redacted] វាសនា ជាក្រមពណ៌សថ្លាទម្ងន់ ៧,០២ (ប្រាំពីរក្បៀសសូន្យពីរ) ក្រាម នេះគឺជា សារធាតុញៀន មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធចំនួន ៧៥,៣៦ (ចិតសិបប្រាំក្បៀសសាមសិបប្រាំមួយ) ភាគរយ ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤០៥៣១/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣។ ហេតុនេះសារធាតុញៀនប្រភេទ មេតំហ្វេតាមីន មានកម្រិតភាពសុទ្ធគិតជា ទម្ងន់ [(៧,០២ x ៧៥,៣៦)/១០០] = ៥,២៩ (ប្រាំក្បៀសម្ភៃប្រាំបួន) ក្រាម និងជាម្សៅពណ៌សទម្ងន់ ០,៣៧ (សូន្យក្បៀសសាមសិបប្រាំពីរ) ក្រាម នេះគឺជា សារធាតុញៀន កេតាមីន ដែលមានកម្រិតភាពសុទ្ធចំនួន ៦៣,៨៦ (ហុកសិបបីក្បៀសប៉ែតសិបប្រាំមួយ) ភាគរយ ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤០៥៣១/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣។ ហេតុនេះសារធាតុញៀនប្រភេទ កេតាមីន មានកម្រិតភាពសុទ្ធគិតជា ទម្ងន់ [(០,៣៧ x ៦៣,៨៦)/១០០] = ០,២៣ (សូន្យក្បៀសម្ភៃបី) ក្រាម។

៤. **ដោយហេតុថា** នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] វាសនា បានឆ្លើយសារភាពថា ៖ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយខ្លួនបានទិញគ្រឿងញៀនយកទៅលក់បន្តអស់រយៈពេលបួនខែហើយដោយទិញបានពីរបីលើកហើយ ដោយក្នុងម្តងៗ ខ្លួនទិញចំនួន ៤០០០០ រៀល ឬក៏ ៥០០០០០រៀល ឬក៏ ៦០០០០០រៀល។ ចំពោះថ្នាំញៀនដែលដកហូតបានមកនេះមានរបស់ខ្លួនតែបន្តិចទេ ដែលខ្លួនទិញមកទុកនៅទីឯខ្លួនសម្រាប់យកទៅប្រើប្រាស់ ក្រៅពីនោះជារបស់ឈ្មោះ [redacted] ចន្ធី។ គ្រឿងញៀនដែលសមត្ថកិច្ចដកហូតពីខ្លួនប្រហែលជាទម្ងន់មួយជ្រុង ឬកន្លះជ្រុង។

៥. **ដោយហេតុថា** នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ចន្ធី បានឆ្លើយសារភាពថា ៖ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយខ្លួនបានកម្មង់ទិញគ្រឿងញៀនពីឈ្មោះ [redacted] វាសនា ចំនួន ៦០០០០០រៀល យកមកដើម្បីលក់បន្ត។ ដំបូងមានម៉ូយតេមកទិញគ្រឿងញៀនពីខ្លួនក្នុងតម្លៃ ៥០០០០

Scanned with CamScanner

រៀល ខ្លួនក៏ទិញគ្រឿងញៀនពីឈ្មោះ [redacted] វាសនា មក យកទៅលក់ទើបត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ហើយបន្តទៅឃាត់ខ្លួនឈ្មោះ [redacted] វាសនា។

៦. **ដោយហេតុថា** នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ប៊ុនឈឿន បានឆ្លើយសារភាពថា ៖ ខ្លួនពិតបានប្រព្រឹត្តដូចការចោទប្រកាន់មែន ខ្លួនបានបបួលឈ្មោះ [redacted] តាំ ទៅហូបអីនៅស្ទូចព្រាក់ ពេលទៅដល់ស្រាប់តែមានសមត្ថកិច្ចឃាត់ខ្លួនទាំងខ្លួន និងឈ្មោះ [redacted] តាំ តែម្តង។ ខ្លួនប្រើប្រាស់គ្រឿងញៀនដោយចូលលុយជាមួយឈ្មោះ [redacted] តាំ មួយម៉ឺនរៀល ទៅ ពីរម៉ឺនរៀល ទិញមកប្រើប្រាស់រួមគ្នា ខ្លួនដោយធ្លាប់ទិញពីឈ្មោះ [redacted] ចន្ធី បានពីរដងដែរ។

៧. **ដោយហេតុថា** នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] តាំ បានឆ្លើយដោះសារថា ៖ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ នៅថ្ងៃដែលត្រូវឃាត់ខ្លួនគឺឈ្មោះ [redacted] ប៊ុនឈឿន បានបបួលខ្លួន ទៅហូបអីជាមួយគ្នានៅស្ទូចព្រាក់ ខ្លួនក៏ទៅជាមួយដោយពុំបានដឹងអ្វីឡើយ ពេលទៅដល់ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនទាំងឈ្មោះ [redacted] ប៊ុនឈឿន តែម្តង។ ពីមុនមកខ្លួនពិតជាធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ [redacted] ប៊ុនឈឿន ក្នុងតម្លៃ ១០០០០រៀល ទៅ ២០០០០រៀល យកទៅប្រើប្រាស់មែន។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនពុំមានគ្រឿងញៀននៅជាប់នឹងខ្លួនទេ។ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាទិញគ្រឿងញៀនយកមកប្រើប្រាស់មែន តែពុំធ្លាប់ជួញដូរគ្រឿងញៀនឡើយ។

៨. **យល់ឃើញថា** ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ចន្ធី និងឈ្មោះ [redacted] ប៊ុនឈឿន នេះតុលាការជឿ ត្បិតមានភាពស៊ីសង្វាក់ទៅនឹងបន្ទាល់របស់នគរបាលយុត្តិធម៌ និងភស្តុតាងដែលមានក្នុងសំណុំរឿង ហេតុនេះ តុលាការជឿជាក់ថា ជនជាប់ចោទ ឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ចន្ធី និងឈ្មោះ [redacted] ប៊ុនឈឿន ពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន ដែលវាជាបទល្មើសមានចែងឱ្យផ្តន្ទាទោសតាមបទបញ្ជត្តិមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៨ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ចំណែកចម្លើយដោះសាររបស់ឈ្មោះ [redacted] តាំ វិញ តុលាការពុំអាចជឿជាក់បានដោយ ហេតុថា ជនជាប់ចោទរូបនេះ ត្រូវបានឃាត់ខ្លួនជាក់ស្តែងជាមួយនឹងជនជាប់ចោទឈ្មោះ [redacted] ប៊ុនឈឿន ដែលមានគ្រឿងញៀននៅជាប់នឹងខ្លួនផងដែរ ផ្អែកតាមបន្ទាល់របស់សមត្ថកិច្ចដែលអាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] តាំ ពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតមែន ដែលវាជាបទល្មើសមានចែងឱ្យផ្តន្ទាទោសតាមបទបញ្ជត្តិមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៨ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩. យោងតាមមាត្រា ៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចែងថា "ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"។ មាត្រា ៤០ កថាខណ្ឌទី៤ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចែងថា "បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមទោសពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល"។ មាត្រា ៤៨ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចែងថា "ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"។ មាត្រា ៤៨ កថាខណ្ឌទី៤ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចែងថា "បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី៣ ត្រូវ

Scanned with CamScanner

ផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមទោសពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល"។ យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចន្ធី ឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] តាំ បានទិញគ្រឿងញៀនប្រភេទ មេតំហ្វេតាមីន និង កេតាមីន យកមកសម្រាប់លក់យកប្រាក់ចំណេញ នេះបញ្ជាក់បានថា ជនជាប់ចោទរូបនេះពិតជាបានប្រព្រឹត្តនូវអំពើ លក់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាបទល្មើសមានចែងក្នុងមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៨ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០. សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ដែលនៅតែតម្កល់ការចោទប្រកាន់ និងស្នើសុំឱ្យតុលាការផ្តន្ទាទោស លើជនជាប់ចោទឈ្មោះ [redacted] ចន្ធី ឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] តាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចវត្តក្រគៀត ផ្លូវជាតិ លេខ៣ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចក្នុងដីកាសន្និដ្ឋានស្តារលេខ ១៤៣០ អ.យ.ផ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកនៅដដែល ការសន្និដ្ឋាននេះពុំទាន់ត្រឹមត្រូវទាំងស្រុងទេ ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] ចន្ធី ឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] តាំ បានជួញដូរនូវសារធាតុញៀនប្រភេទ កេតាមីន ដែលសារធាតុញៀនប្រភេទនេះ គឺមានបញ្ញត្តិថាជាបទល្មើស និងកំណត់ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌទី៣ និងកថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហេតុនេះ គប្បីតុលាការប្រកាសទោសទៅលើជនជាប់ចោទឈ្មោះ [redacted] ចន្ធី ឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ប៊ុនឆៃ និងឈ្មោះ [redacted] តាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចវត្តក្រគៀត ផ្លូវជាតិលេខ៣ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៤ និងមាត្រា ៤៨ កថាខណ្ឌទី៣ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១. មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ [redacted] ចន្ធី ឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ប៊ុនឆៃ និងឈ្មោះ [redacted] តាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចវត្តក្រគៀត ផ្លូវជាតិលេខ៣ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមាន ចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៤ និងមាត្រា ៤៨ កថាខណ្ឌទី៣ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១២. វត្ថុចាប់យកមាន ៖

ក. ក្រាមពណ៌សថ្លា ទម្ងន់ ១៧,១៧ (ដប់ប្រាំពីរក្បៀសដប់ប្រាំពីរ)ក្រាម (មេតំហ្វេតាមីន) ជារបស់ឈ្មោះ [redacted] ចន្ធី និងឈ្មោះ [redacted] ប៊ុនឈឿន

ខ. ក្រាមពណ៌សថ្លា ទម្ងន់ ៧,០២ (ប្រាំពីរក្បៀសសូន្យពីរ)ក្រាម (មេតំហ្វេតាមីន) ជារបស់ឈ្មោះ [redacted] វាសនា

គ. ម្សៅម៉ត់ពណ៌ស ទម្ងន់ ០,៣៧ (សូន្យក្បៀសសាមសិបប្រាំពីរ) ក្រាម (កេតាមីន) ជារបស់ឈ្មោះ [redacted] វាសនា

ដូចមានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ១៤៥ រ.វ.ត/២៣ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ គប្បីសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោស ៖

ក. ឈ្មោះ [redacted] **ចន្ធី** ភេទ ប្រុស ឈ្មោះ [redacted] **ប៊ុនឈឿន** ភេទ ប្រុស និង ឈ្មោះ [redacted] **វាសនា** ភេទ ប្រុស ដែលមានអត្តសញ្ញាណដូចខាងលើ ជាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល **២ (ពីរ) ឆ្នាំ និង ៦ (ប្រាំមួយ) ខែ** និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន **៤ ០០០ ០០០ (បួនលាន) រៀល**

ខ. ឈ្មោះ [redacted] **តាំ** ភេទ ប្រុស ដែលមានអត្តសញ្ញាណដូចខាងលើ ជាក់ពន្ធនាគារកំណត់រយៈពេល **២ (ពីរ) ឆ្នាំ** និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន **៤ ០០០ ០០០ (បួនលាន) រៀល**

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចវត្តក្រគៀត ផ្លូវជាតិលេខ៣ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៨ កថាខណ្ឌទី៤ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

២. វិបរអូសតាមច្បាប់នូវ ៖

ក. ក្រាមពណ៌សថ្លា ទម្ងន់ ១៧,១៧ (ដប់ប្រាំពីរក្បៀសដប់ប្រាំពីរ)ក្រាម (មេតំហ្វេតាមីន) ជារបស់ឈ្មោះ [redacted] ចន្ធី និងឈ្មោះ [redacted] ប៊ុនឈឿន

ខ. ក្រាមពណ៌សថ្លា ទម្ងន់ ៧,០២ (ប្រាំពីរក្បៀសសូន្យពីរ)ក្រាម (មេតំហ្វេតាមីន) ជារបស់ឈ្មោះ [redacted] វាសនា

គ. ម្សៅម៉ត់ពណ៌ស ទម្ងន់ ០,៣៧ (សូន្យក្បៀសសាមសិបប្រាំពីរ) ក្រាម (កេតាមីន) ជារបស់ឈ្មោះ [redacted] វាសនា ដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ១៤៥ រ.វ.ត/២៣ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ចន្ធី** ឈ្មោះ [redacted] **ប៊ុនឈឿន** ឈ្មោះ [redacted] **វាសនា** និងឈ្មោះ [redacted] **តាំ** និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ចន្ធី** ឈ្មោះ [redacted] **ប៊ុនឈឿន** ឈ្មោះ [redacted] **វាសនា** និងឈ្មោះ [redacted] **តាំ**៕

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

ក្រឡាបញ្ជីសវនាការ	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
[redacted]			

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣

ឃានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner